# ទំនុកដំកើង ១២៧

អ្នកនិពន្ធ រុហ្វ លេភិឡារ

ទំនុកដំកើងនេះពិភាក្សាអំពីបញ្ហាសំខាន់បីជាមួយនឹងមនុស្សទាំងអស់គឺ ការសង់ផ្ទះ សុវត្ថិភាព ហើយនិងការបង្កើតក្រុមគ្រួសារ។ សកម្មភាពនិងការថប់បារម្ភរបស់មនុស្សភាគច្រើនទាក់ទងនឹងបញ្ហាទាំងបីនេះ។ គំនិតចំបងនៃទំនុកដំកើងនេះគឺថា យើងមិនអាចធ្វើអ្វីបានទាំងអស់ប្រសិនបើគ្មានព្រះអម្ចាស់។ ទំនុកដំកើងនេះមិនមានសេចក្តីអធិស្ឋានឬការសរសើរតម្កើងណាទៅចំពោះព្រះនោះទេ ប៉ុន្តែដូចជាកណ្ឌសុភាសិតដែរដែលមានការសង្កេតពិនិត្យលើសកម្មភាពជីវិតនិងការរស់នៅដោយកោតខ្លាចព្រះ។ ទំនុកដំកើងនេះព្រមានយើង ពីព្រោះថ្វីបើសាឡូម៉ូនជា «អ្នកនិពន្ធ» ក៏ដោយ ក៏នៅចុងបញ្ចប់ជីវិតរបស់គាត់ សាឡូម៉ូនមិនបានដើរតាមប្រាជ្ញានៃទំនុកដំកើងនេះទេ។ នគររបស់គាត់ត្រូវបានបំផ្លាញ (១ពង្សាវតារក្សត្រ ១១:១១...) ហើយអាពាហ៍ពិពាហ៍របស់គាត់គឺជាការបដិសេធព្រះដែលមានហមន្តរាយមួយ (១ពង្សាវតារក្សត្រ ១១.១...)។

ផ្នែកទាំងពីរនៃទំនុកដំកើងនេះ (ខ. ១-២ និងខ. ៣-៥) ប្រកាសថា មានតែអ្វីដែលមកពីព្រះប៉ុណ្ណោះដែលពិតជាខ្លាំង។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យថា «ផ្ទះ» មានអត្ថន័យពីរ (លំនៅ ឬក្រុមគ្រួសារ)។ ផ្នែកទីមួយនៃទំនុកដំកើងនិយាយអំពីលំនៅ ឯផ្នែកទីពីរនិយាយអំពីក្រុមគ្រួសារ។ នៅក្នុងភាសាហេព្រើក៏មានភាពស្រដៀងគ្នាមួយរវាងផ្នែកទាំងពីរនៃទំនុកដំកើងនេះដោយសារតែភាពស្រដៀងគ្នារវាងពាក្យហេព្រើសំរាប់ «អ្នកសង់» (ខ. ១) *bōnîm* និង «កូនចៅ» (ខ. ៣) *bānîm*។ ផ្នែកទាំងពីរនៃទំនុកដំកើងនេះត្រូវបានពន្យល់បង្ហាញដោយកថាខ័ណ្ឌទីមួយនិងចុងក្រោយនៃលោកុប្បត្តិ ១១ ដែលមនុស្សសាងសង់ប៉មបាបិលសំរាប់សិរីល្អនិងសន្តិសុខរបស់ខ្លួន ប៉ុន្តែត្រូវបានព្រះបំផ្លិចបំផ្លាញហើយកំចាត់កំចាយទៅ ប៉ុន្តែថេរ៉ាទទួលបានពីព្រះនូវកូនប្រុសម្នាក់ដែលតាមរយៈកូនប្រុសនេះ ព្រះបានប្រទានពរដល់ពិភពលោក។ សូមមើលនេហេមា ៦:១៥-៧:៥ សំរាប់រឿងមួយទៀតដែលសំដែងសេចក្តីពិតផ្សេងៗនៃទំនុកដំកើងនេះ។

**ខ. ១** ខ. ១និង២ពិភាក្សាអំពីសកម្មភាពពីររបស់មនុស្សគឺការសង់ផ្ទះនិងសុវត្ថិភាព។ ដោយសារសកម្មភាពនិមួយៗមានតែលទ្ធភាពពីរប៉ុណ្ណោះ គឺជាការធ្វើរបស់ព្រះអម្ចាស់ ឬគឺជាការឥតប្រយោជន៍ ហើយគ្មានជម្រើសទីបីនោះទេ។ ប្រវត្តិសាស្ត្ររបស់អ៊ីស្រាអែលបង្ហាញអំពីសេចក្តីពិតរបស់ខ.១។ នៅពេលទីក្រុងផ្សេងៗត្រូវបានបំផ្លាញ នោះមិនមែនដោយព្រោះពួកគេខ្វះពួកយាមល្បាតនោះទេ។ ទីក្រុងទាំងនោះត្រូវបានបំផ្លាញដោយព្រោះការវិនិច្ឆ័យរបស់ព្រះបានធ្លាក់មកលើពួកគេដោយសារតែការបះបោរប្រឆាំងរបស់ពួកគេចំពោះព្រះ។ សូម្បីតែពួកគេមានពួកយាមល្បាតច្រើនដែលធ្វើការល្អហើយមានពលទ័ពខ្លាំងពូកែ ក៏មិនអាចការពារពួកគេមិនឲ្យវិនាសបានដែរ ដូច្នេះពួកយាមល្បាតកំពុងឈរយាមជាឥតប្រយោជន៍។ យើងឃើញសេចក្តីពិតទូទៅដូចគ្នានេះនៅក្នុងប្រវត្តិសាស្ត្រ។ ការប៉ុនប៉ងរបស់សង្គមផ្សេងៗក្នុងការសាងសង់សន្តិភាពបន្តបរាជ័យដោយព្រោះបើសិនព្រះអម្ចាស់មិនថែរក្សាពួកគេនោះទេ នោះការប៉ុនប៉ងទាំងប៉ុន្មានរបស់ពួកគេជាឥតប្រយោជន៍។

**ខ. ២** នៅពេលសកម្មភាពរបស់មនុស្សមិនកំពុងជោគជ័យដូចជាយើងចង់បាន ប្រសិនបើវាមិននាំទៅកាន់ជីវិតដែលយើងចង់បាន ពេលខ្លះយើងគិតថាដំណោះស្រាយគឺត្រូវតែធ្វើការឲ្យខ្លាំងជាងនេះទៀត គឺត្រូវមានសកម្មភាពច្រើនបន្ថែមទៀត។ ខនេះបង្ហាញថាការធ្វើការខ្លាំងជាងនៅតែមិនមែនជាចំលើយដដែល វាគ្រាន់តែអាចធ្វើអ្នកកាន់នឿយហត់បន្ថែមទៀតតែប៉ុណ្ណោះ។ វាមិនកំពុងនិយាយថាការងាររបស់យើងនឹងបរាជ័យទាំងស្រុងនោះទេ មនុស្សពិតជាមានអាហារបរិភោគនិងផ្ទះសម្បែង ប៉ុន្តែនេះមិននាំទៅដល់កន្លែងណាទេ លើកលែងតែទៅដល់ជីវិតមួយដែលនឿយហត់ពីការងារ។ ការប្រើរូបភាពនៅក្នុងខ.១ ផ្ទះនិងទីក្រុងអាចមាននៅ ប៉ុន្តែសួរថាតើពួកវាមានតំលៃស្មើនឹងការប្រឹងប្រែងរបស់យើងដែរឬទេ?

*ដ្បិតទ្រង់ប្រោសប្រទានឲ្យពួកស្ងួនភ្ងារបស់ទ្រង់បានដេកលក់សប្បាយ:* ចាប់ពីចំនុចនេះទៅ ទំនុកដំកើងនេះផ្តល់នូវការផ្លាស់ប្តូរនៃភាពបរាជ័យរបស់យើង។ ការប្រោសប្រទានឲ្យបានដេកលក់មិនមែនជារូបភាពនៃការអនុញ្ញាតឲ្យយើងមានភាពខ្ជិលច្រអូសនោះទេ

ប៉ុន្តែនៅក្នុងជីវិតរបស់យើងដែលមានពរតាមរយៈការងារដោយអំណរ យើងក៏អាចមានសេចក្តីសំរាកដោយគ្មានកង្វល់ផងដែរ ពីព្រោះយើងទុកចិត្តលើទ្រង់ហើយទ្រង់ផ្គត់ផ្គង់។ ប្រយោគនេះក្នុងភាសាហេព្រើពិបាកនឹងបកប្រែ ហើយអាចបកប្រែពីរយ៉ាង ដូច្នេះព្រះគម្ពីរខ្មែរបរិសុទ្ធបកប្រែវាថា «ដ្បិតទ្រង់ប្រោសប្រទានឲ្យពួកស្ងួនភ្ងារបស់ទ្រង់បានដេកលក់សប្បាយ» ហើយគ.ខ.ប បកប្រែវាថា «ដ្បិតព្រះអម្ចាស់ប្រទានអាហារដល់អ្នកអ្នកដែលព្រះអង្គស្រលាញ់ក្នុងពេលដែលគេកំពុងតែដេកលក់»។ សាស្ត្រាចារ្យព្រះគម្ពីរភាគច្រើនយល់ស្របជាមួយនឹងការបកប្រែនៅក្នុងព្រះគម្ពីរខ្មែរបរិសុទ្ធ។ ខចាប់ផ្តើមមានឥរិយាបថពីរផ្ទុយនឹងព្រះ(ការពឹងផ្អែក និងឯករាជ្យភាព) ពួកវាមិនមែនជាឥរិយាបថពីរផ្ទុយនឹងការងារនោះទេ។ ដូច្នេះ ប្រសិនបើខនេះមិនមែនជាឥរិយាបថពីរផ្ទុយនឹងការងារ នោះវាមិនត្រូវនិយាយថាព្រះប្រទានពរដល់អស់អ្នកណាដែលទ្រង់ស្រលាញ់ដើម្បីឲ្យពួកគេបានដេកលក់ជាជាងបានធ្វើការងារនោះឡើយ។

**ខ. ៣-៥** ព្រះគម្ពីរបង្រៀនថាព្រះ «បើកផ្ទៃ» ឬ «បិទ» ផ្ទៃ (លោកុប្បត្តិ ២៩:៣១, ៣០:២)។ កូនចៅមិនមែនជាការសំរេចបានរបស់យើងនោះទេ តែជាអំណោយទានដែលមកពីទ្រង់វិញ (ខ. ៣)។ មនុស្សនៅសម័យនោះអាចយល់រូបភាពនៅក្នុងខ.៤ បានយ៉ាងងាយស្រួល។ កូនប្រុសម្នាក់ដែលឪពុកម្តាយវ័យក្មេងផ្តល់កំណើតនឹងបានខ្លាំងនៅពេលដែលឪពុកម្តាយមានវ័យកាន់តែចាស់និងកាន់តែខ្សោយ។ កូនប្រុសនោះអាចការពារក្រុមគ្រួសារដូចជាព្រួញនៅក្នុងដៃរបស់អ្នកចំបាំង។ ករណីផ្សេងៗដែលទាមទារការវិនិច្ឆ័យអាចត្រូវគេនាំមកឯទ្វារក្រុង ប៉ុន្តែក្រុមគ្រួសារមួយដែលខ្លាំងនឹងមិនចាញ់ពួកខ្មាំងសត្រូវដែលអយុត្តិធម៌នោះទេ។

**ការអនុវត្ត**

ទំនុកដំកើងនេះផ្តល់ឲ្យនូវប្រាជ្ញាសំរាប់សកម្មភាពជីវិតរបស់យើង។ យើងត្រូវតែធ្វើការងារនិងរីករាយនឹងព្រះពរដែលព្រះប្រទានឲ្យ ប៉ុន្តែនៅពេលយើងធ្វើការងារ យើងត្រូវតែដឹងថាយើងពឹងផ្អែកលើព្រះទាំងស្រុង។ ការដឹងនេះមានឥទ្ធិពលក្នុងរបៀបពីរ គឺប្រសិនបើគ្មានទ្រង់ នោះការងាររបស់យើងនឹងជាឥតប្រយោជន៍ ប្រសិនបើមានទ្រង់ នោះយើងទទួលបាននូវសេចក្តីសំរាកហើយមិនចាំបាច់ថប់បារម្ភនោះឡើយ។ ប្រាជ្ញានៅទីនេះស្រដៀងគ្នាទៅនឹងអ្វីដែលព្រះយេស៊ូវបានបង្រៀននៅក្នុងម៉ាថាយ ៦:១៩-៣៤។

## Bibliography


Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Keil, C. F., & Delitzsch, F. (1996). *Vol. 5*: *Commentary on the Old Testament* . Peabody, MA: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries (465–467). Nottingham, England: Inter-Varsity Press.

Wilcock, M. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.